

# ខ្ញុំចង់ជឿដែរ ប៉ុន្តែ....

## ឆ្លើយតបសំណួរ ដែលទាក់ទងនឹង

ពិធីបុណ្យជ្រមុជទឹក, ការទៅព្រះវិហារ,
ការប្តេជ្ញាចិត្តរស់នៅជាគ្រីស្ទបរិស័ទ



# ខ្ញុំចង់ជឿដែរ

# ប៉ុន្តែ...

## ឆ្លើយតបសំណួរ ដែលទាក់ទងនឹង

*ពិធីបុណ្យជ្រមុជទឹក ការទៅព្រះវិហារ ការប្តេជ្ញាចិត្តរស់នៅជាគ្រីស្ទបរិស័ទ*

EDITORS: Chia Poh Fang,
Amos Khan, Khan Hui Neon,
Leslie Koh
DESIGN & LAYOUT: Felix Xu
COVER & CONTENT PHOTOS:
Shutterstock.com

រក្សាសិទ្ធិគ្រប់យ៉ាងដោយ នំម៉ាណាប្រចាំថ្ងៃ
© 2020 (website: khmer-odb.org)
បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ ភាសាខ្មែរ បកប្រែចាស់ ឆ្នាំ១៩៥៤ ដោយការអនុញ្ញាតិ និងរក្សាសិទ្ធិដោយសមាគមន៍ព្រះគម្ពីរសកល (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។



ពេលដែលស៊ូ អាន(Soo Ann) បានឮគេនិយាយប្រាប់នាង អំពីព្រះយេស៊ូវ និងអំពីការដែលព្រះអង្គប្រទានការអត់ទោសបាប និងជីវិតអស់កល្ប នាងមានអារម្មណ៍ថា ទីបំផុត នាងបានរកឃើញព្រះ ដែលនាងគួរតែជឿហើយ។ នាងជឿថា ព្រះយេស៊ូវជាព្រះ ដូចនេះ នាងចង់ទទួលជឿព្រះយេស៊ូវ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះនៃជីវិតនាង។ ប៉ុន្តែ នាងមានឧបសគ្គមួយ។ នាងបានចម្រើនវ័យធំឡើង ក្នុងគ្រួសារមួយដែលប្រកាន់ខ្ជាប់តាមទំនាមទំលាប់ប្រពៃណី របស់ជនជាតិនាង ដូចនេះ នាងខ្លាចឪពុកម្តាយរបស់នាងបដិសេធ។ នាងមិនដឹងថា ពួកគេនឹងស្តីឲ្យនាងយ៉ាងណាខ្លះទេ?

*ប៉ុន្តែ នាងមានការភ្ញាក់ផ្អើលណាស់ ពេលដែលម្តាយរបស់នាងមិនបានប្រឆាំងនឹងនាងទាំងស្រុង។ គាត់ប្រាប់នាងថា "ជីវិតរបស់កូន គឺជាកម្មសិទ្ធិរបស់កូន ដូចនេះ កូនចង់ជឿអីក៏ជឿទៅ"។ ប៉ុន្តែ គាត់ក៏បានបន្ថែមទៀតថា ស៊ូ អាន មិនត្រូវទទួលបុណ្យជ្រមុជទឹកឡើយ ទាល់តែឪពុកម្តាយនាងស្លាប់សិន។ គាត់ថា "កូនជាកូនតែមួយក្នុងគ្រួសារ។ កូនត្រូវតែធ្វើពិធីសែនព្រេន តាមប្រពៃណី នៅក្នុងពិធីបុណ្យសពរបស់ប៉ា និងម៉ាក់។ បើកូនទទួលបុណ្យជ្រមុជទឹកហើយ តើបាននរណាធ្វើពិធីនេះ?"*

បញ្ហានេះ បានធ្វើឲ្យស៊ូ អាន មានការពិបាកចិត្តយ៉ាងខ្លាំង។ នាងចង់ដើរតាមព្រះយេស៊ូវ ប៉ុន្តែ ក្នុងនាមនាងជាកូនទោលក្នុងគ្រួសារ នាងចង់បំពេញបំណងរបស់ឪពុកម្តាយផងដែរ។ ដូចនេះ នាងក៏

មានការស្ទាក់ស្ទើរ។ នាងគិតថា បើនាងមិនអាចទទួលបុណ្យជ្រមុជទឹកទេ នោះនាងមិនអាចក្លាយជាគ្រីស្ទបរិស័ទបានឡើយ។

ហ៊ែនរី(Henry) ក៏មានការស្ទាក់ស្ទើរ នៅក្នុងការសម្រេចចិត្តផងដែរ តែដោយសារមូលហេតុផ្សេងពីនេះ។ គាត់មានការជាប់រវល់នៅថ្ងៃចុងសប្តាហ៍ តែរវល់នឹងរឿងល្អៗទេ។ នៅថ្ងៃសៅរ៍ គាត់ចំណាយពេលជាមួយក្រុមគ្រួសារគាត់។ នៅថ្ងៃអាទិត្យ គាត់លេងកីឡាវាយសីពីរបីទឹក ជាមួយមិត្តភក្តិគាត់។ ពុំនោះទេ បើសិនជាគាត់មានអារម្មណ៍អស់កម្លាំង គាត់ក៏បានបន្តគេងនៅលើគ្រែ និងសម្រាកនៅផ្ទះ។ គាត់ចូលចិត្តកាលវិភាគនេះ ព្រោះគាត់ងាយស្រួលបត់បែន។ គាត់មិនចង់ក្រោកពីព្រលឹម ដើម្បីរៀបចំខ្លួន ទៅព្រះវិហារ រៀងរាល់ថ្ងៃអាទិត្យនោះទេ។ គាត់លើកហេតុផលថា “បើសិនជាខ្ញុំ ក្លាយជាគ្រីស្ទាន ខ្ញុំនឹងបាត់បង់សេរីភាពនេះមិនខានទេ”។




## ចូរបន្តសួរសំណួរ និងស្វែងរកសេចក្តីពិត

អ្នកប្រហែលជាមានបញ្ហា ដូចស៊ូអាន និងហ៊ែនរីផងដែរ។ ពុំនោះទេ អ្នកប្រហែលជាមានការសង្ស័យ និងមានសំណួរ ដែលអ្នកត្រូវការចម្លើយ មុនពេលអ្នកអាចធ្វើការសម្រេចចិត្តរស់នៅជាគ្រីស្ទាន។ សូមកុំព្រួយបារម្ភឡើយ។ វាជារឿងធម្មតាទេ ដែលយើងមានការសង្ស័យ និងមានសំណួរដូចនេះ មុនពេលយើងធ្វើការសម្រេចចិត្តដ៏សំខាន់មួយ។ ការនេះបានបង្ហាញថា អ្នកបានគិតដិតដល់ អំពីជំនឿរបស់គ្រីស្ទបរិស័ទ ហើយចង់មានការបកស្រាយឲ្យបានច្បាស់លាស់ អំពីបញ្ហាមួយចំនួន មុនពេលអ្នកទទួលជឿព្រះអង្គ។ យើងខ្ញុំយល់អំពីអារម្មណ៍របស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យបន្តស្វែងយល់អំពីព្រះអង្គ។ ចូរបន្តសួរសំណួរ និងស្វែងរកសេចក្តីពិត។ ព្រះទ្រង់នឹងឆ្លើយតប ព្រោះព្រះអង្គស្រឡាញ់អ្នក។ ព្រះអង្គសព្វព្រះទ័យឲ្យអ្នកស្គាល់ព្រះអង្គ ដើម្បីឲ្យអ្នកបានទទួលអំណោយ នៃសេចក្តីសង្គ្រោះ ដែលព្រះអង្គបានប្រទានតាមរយៈព្រះយេស៊ូវ។

ទន្ទឹមនឹងនេះ យើងខ្ញុំនឹងព្យាយាមឆ្លើយសំណួរដែលគេច្រើនតែចោទសួរ អំពីអត្ថន័យនៃការរស់នៅជាគ្រីស្ទបរិស័ទ។

# ការប្តេជ្ញាចិត្តដ៏ធំមួយ

**អ្នកខ្លះមានការស្ទាក់ស្ទើរ នៅក្នុងការដើរតាមព្រះ ព្រោះពួកគេគិតថា ជំនឿរបស់គ្រីស្ទបរិស័ទមានការតម្រូវជាច្រើន។** ពួកគេប្រហែលជាគិតថា ដើម្បីក្លាយជាគ្រីស្ទបរិស័ទ ពួកគេចាំបាច់ត្រូវក្លាយជាមនុស្ស "ល្អ" ឬត្រូវប្រារព្ធពិធី និងអនុវត្តតាមការតម្រូវជាច្រើន ដែលមានដូចជាការទទួលពិធីបុណ្យជ្រមុជទឹក និងការទៅព្រះវិហារជាដើម។ អ្នកក៏ប្រហែលជាឆ្ងល់ផងដែរថា ដើម្បីក្លាយជាគ្រីស្ទបរិស័ទ តើអ្នកត្រូវធ្វើការប្តេជ្ញាចិត្ត ដែលអ្នកមិនទាន់បានត្រៀមខ្លួនឬ? ខ្ញុំសូមបកស្រាយចម្ងល់ទាំងនេះ ដូចតទៅ :

## ១. ហេតុអ្វីខ្ញុំចាំបាច់ត្រូវទទួលបុណ្យជ្រមុជទឹក?

**ការទទួលបុណ្យជ្រមុជទឹក គឺជាអ្វីដែលព្រះយេស៊ូវបានផ្តន្ទាកាត់ដោយផ្ទាល់ ហើយព្រះអង្គក៏បានប្រាប់យើង ឲ្យទទួលបុណ្យជ្រមុជទឹកផងដែរ។** ព្រះវិហារខ្លះធ្វើពិធីបុណ្យជ្រមុជទឹក ដោយឲ្យអ្នកលិចខ្លួនចូលទៅក្នុងទឹក ហើយព្រះវិហារខ្លះទៀត គ្រាន់តែបន្តក់ទឹក ឬចាក់ទឹកតែបន្តិច ពីលើក្បាលអ្នក នៅចំពោះមុខពួកជំនុំទាំងមូល។

ការទទួលបុណ្យជ្រមុជទឹក គឺជាការប្រកាស់ជាសាធារណៈថា យើងបានទទួលជឿព្រះយេស៊ូវ។ គឺជាការបង្ហាញចេញនូវសញ្ញានៃការផ្លាស់ប្រែ ដែលកំពុងតែមានក្នុងជីវិតយើង គឺជាការប្រកាស់ថា យើងបានសម្រេចចិត្តដើរតាមព្រះយេស៊ូវ និងជានិមិត្តរូបតំណាងឲ្យការចូលរួមរបស់យើង នៅក្នុងការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ។ គឺដូចដែលព្រះគម្ពីរបានចែងថា "យើងទាំងប៉ុន្មានដែលបានទទួលបុណ្យជ្រមុជក្នុងព្រះយេស៊ូវគ្រីស្ទ នោះគឺបានទទួលជ្រមុជក្នុងសេចក្តីសុគតនៃទ្រង់ដែរ ដូច្នេះ យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតាដែរ"(រ៉ូម ៦:៣-៤)។



▶ ការទទួលបុណ្យជ្រមុជទឹក គឺជាការប្រកាស់ជាសាធារណៈថា យើងបានទទួលជឿព្រះយេស៊ូវ។

## ២. តើខ្ញុំត្រូវតែទទួលបុណ្យជ្រមុជទឹក ដើម្បីឲ្យបានសង្គ្រោះឬ?

**ពេលដែលព្រះវិហារលើកទឹកចិត្តអ្នក ឬជំរុញអ្នកឲ្យទទួលបុណ្យជ្រមុជទឹក បន្ទាប់ពីអ្នកទើបតែបានទទួលជឿព្រះ** អ្នកប្រហែលជាឆ្ងល់ថា តើអ្នកត្រូវតែទទួលបុណ្យជ្រមុជទឹកដើម្បីឲ្យបានសង្គ្រោះឬ?

ខ្ញុំសូមឆ្លើយយ៉ាងខ្លីថា : ការទទួលបុណ្យជ្រមុជទឹក គឺជាការប្រកាស់ថា យើងបានទទួលសេចក្ដីសង្គ្រោះហើយ តែវាមិនមែនជាអ្វីដែលយើងត្រូវតែធ្វើ ដើម្បីឲ្យបានសង្គ្រោះនោះទេ។ ព្រះគម្ពីរបានបញ្ជាក់ច្បាស់ថា ព្រះយេស៊ូវបានសង្គ្រោះយើង ដោយព្រះគុណរបស់ព្រះអង្គ ពេលដែលយើងជឿព្រះអង្គ គឺជាព្រះគុណដែលបានបង្ហាញចេញមក តាមរយៈការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ។ គឺដូចមានសេចក្ដីចែងថា “ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន”(អេភេសូរ ២:៨-៩)។

គ្មានពិធីបុណ្យ ប្រពៃណី ឬការប្រព្រឹត្តមួយណា ដែលអាចសង្គ្រោះយើងនោះឡើយ។ ដូចដែលយើងបាននិយាយរួចហើយ ពិធីបុណ្យជ្រមុជទឹក គឺជាអ្វីដែលព្រះយេស៊ូវសព្វព្រះទ័យឲ្យយើងធ្វើ ព្រោះពីធីបុណ្យជ្រមុជទឹក ជាការបង្ហាញថា យើងបានសម្រេចចិត្តដើរតាមព្រះអង្គ។ គឺជាការប្រកាស់ជាសាធារណៈថា យើងបានទទួលជឿព្រះអង្គ។ គ្រួសាររបស់អ្នកប្រហែលជារាំងមិនឲ្យអ្នកទទួលបុណ្យជ្រមុជទឹក។ អ្នកប្រហែលជាចាំបាច់ត្រូវពន្យល់ពួកគេ ហើយពន្យល់ អំពីមូលហេតុ ដែលអ្នកចង់ទទួលបុណ្យជ្រមុជទឹក។ ចូរទូលសូមប្រាជ្ញា និងកម្លាំងមកពីព្រះ ដើម្បីនិយាយទៅកាន់ពួកគេ កុំឲ្យមានជម្លោះ ហើយជ្រើសរើសពេលវេលាដ៏សមរម្យ ដើម្បីទទួលបុណ្យជ្រមុជទឹក។



**ការទទួលបុណ្យជ្រមុជទឹក គឺជាការបង្ហាញថា យើងបានសម្រេចចិត្តដើរតាមព្រះយេស៊ូវហើយ។**



▶ បងប្អូនរួមជំនឿ អាចផ្តល់ជំនួយ ផ្តល់យោបល លើកទឹកចិត្ត និងអធិស្ឋានឲ្យយើង។

## ៣. ហេតុអ្វីគ្រីស្ទបរិស័ទចូលចិត្តនិយាយច្រើនយ៉ាងនេះ អំពីការទៅព្រះវិហារ? បន្ទាប់ពីខ្ញុំបានក្លាយជាគ្រីស្ទបរិស័ទហើយ តើខ្ញុំត្រូវទៅព្រះវិហារដែរឬ?

**ដើម្បីឆ្លើយសំណួរនេះ ជាដំបូង យើងចាំបាច់ត្រូវដឹងថា ព្រះវិហារគឺជាអ្វី។**

ពេលណាអ្នកថ្វាយជីវិតដាច់ដល់ព្រះយេស៊ូវ គឺអ្នកបានចូលរួមជាមួយមនុស្សមួយក្រុម ដែលបានធ្វើការសម្រេចចិត្តដូចគ្នា។ សាវ័កប៉ុល ដែលជាអ្នកដឹកនាំគ្រីស្ទបរិស័ទ នៅសម័យដើម បានធ្វើការកត់សំគាល់ថា “អ្នករាល់គ្នាមិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ គឺជាជាតិតែ១នឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ”(អេភេសូរ ២:១៩)។ ដោយសារយើងបានរួបរួមតែមួយ ក្នុងជំនឿ នោះព្រះទ្រង់បានត្រាស់ហៅយើង ឲ្យថ្វាយបង្គំព្រះអង្គជាមួយគ្នា។ ព្រះគម្ពីរបានជំរុញអ្នកជឿ ឲ្យជួបជុំគ្នាជាទៀងទាត់ ដើម្បីឲ្យយើងអាចសរសើរដំកើងព្រះជាមួយគ្នា រៀនព្រះគម្ពីរជាមួយគ្នា លើកទឹកចិត្តគ្នាទៅវិញទៅមក ហើយជួយគ្នាទៅវិញទៅមក។ ខណៈពេលដែលយើងព្យាយាម ចូលទៅជិតព្រះ ក្នុងអំឡុងពេលដ៏ពិបាកក្នុងជីវិតយើង បងប្អូនរួមជំនឿរបស់យើង អាចផ្តល់ជំនួយ ផ្តល់យោបល លើកទឹកចិត្ត និងអធិស្ឋានឲ្យយើង។

គ្រីស្ទបរិស័ទដែលជាបងប្អូនរួមជំនឿ ជួបជុំគ្នាថ្វាយបង្គំព្រះ ជាទៀងទាត់ ក្នុងនាមជាពួកជំនុំរបស់ព្រះអង្គ។ ការជួបជុំនោះ អាចជាការជួបជុំដែលមានការរៀបចំ ឬមានលក្ខណៈផ្លូវការ នៅក្នុងអគារ ដែលបានរៀបចំសម្រាប់ការជួបជុំ និងថ្វាយបង្គំ ឬការជួបជុំមិនផ្លូវការ នៅតាមផ្ទះនរណាម្នាក់។ ព្រះយេស៊ូវបានសន្យាថា “ដ្បិតកន្លែងណាដែលមាន២ឬ៣អ្នក ប្រជុំជាមួយគ្នា ដោយនូវឈ្មោះខ្ញុំ នោះខ្ញុំក៏នៅកណ្តាលចំណោមអ្នកទាំងនោះដែរ”(ម៉ាថាយ ១៨:២០)។ ខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យចូលរួមជាមួយព្រះវិហារ ក្នុងតំបន់ដែលអ្នករស់នៅ ដើម្បីឲ្យអ្នកអាចលូតលាស់ ក្នុងជំនឿនៅទីនោះ។

បើសិនជាអ្នកជួបបញ្ហាប្រឈម ដែលធ្វើឲ្យពិបាកចូលរួមថ្វាយបង្គំនៅព្រះវិហារ ឬមានការប្រឆាំងពីក្រុមគ្រួសារ និងសហគមន៍របស់អ្នក យើងខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យទូលសូមប្រាជ្ញា និងជំនួយមកពីព្រះ ដើម្បីជួយអ្នកឲ្យស្វែងរកមធ្យោបាយ ដើម្បីទៅជួបប្រជុំជាមួយបងប្អូនរួមជំនឿ។

## ៤. បើខ្ញុំក្លាយជាគ្រីស្ទបរិស័ទ តើខ្ញុំត្រូវធ្វើអ្វីខ្លះ? តើមានន័យថា ខ្ញុំត្រូវតែរស់នៅជាមនុស្សល្អឬ?

**មនុស្សជាច្រើនគិតថា ខ្លួនមិនសក្តិសម នឹងទទួលការអត់ទោសបាបពីព្រះ និងមិនសមនឹងឲ្យព្រះអង្គទទួលយកពួកគេ ព្រោះពួកគេមានអំពើបាប ភាពកម្សោយ និងចរិយាសម្បត្តិដែលខ្វះចន្លោះ។** ពួកគេប្រហែលជានៅប្រកាន់ទោសខ្លួនឯង ដែលបានប្រព្រឹត្តកាលពីមុន ឬមានអារម្មណ៍ថា មិនអាចផ្តាច់ការញៀននឹងអ្វីមួយ និងមានចំណុចខ្វះខាតណាមួយ។ អ្នកក៏ប្រហែលជានិយាយថា “ខ្ញុំក៏ជឿថា ព្រះយេស៊ូវបានសុគត និងមានព្រះជន្មរស់ឡើងវិញ ដើម្បីសង្គ្រោះខ្ញុំឲ្យរួចពីបាប ហើយខ្ញុំចង់ដើរតាមព្រះអង្គ។ ប៉ុន្តែ ខ្ញុំមិនគិតថា ខ្ញុំអាចរស់នៅ តាមការតម្រូវរបស់ព្រះអង្គបានទេ។ ខ្ញុំមិនមានលក្ខណៈល្អគ្រប់គ្រាន់ឡើយ”។ ខ្ញុំសូមលើកទឹកចិត្តអ្នកថា អ្នកបានសង្គ្រោះ មិនមែនដោយសារអ្នកជាមនុស្សល្អនោះឡើយ។ នេះជាសេចក្តីពិត។ យើងម្នាក់ៗបានសង្គ្រោះ ដោយសារព្រះគុណព្រះ គឺមិនមែនដោយសារចរិយាសម្បត្តិដ៏ល្អនោះឡើយ។ ព្រះគម្ពីរបានចែងថា ព្រះយេស៊ូវបានរាប់រកស្ត្រីរកស៊ីផ្លូវភេទ មន្ត្រីពុករលួយ មនុស្សកំផិត និងមនុស្សដែលគេស្អប់ខ្ពើមបំផុត។ តាមពិត ព្រះអង្គបានយកព្រះទ័យទុកដាក់យ៉ាងខ្លាំង មកលើអ្នកដែលមានអារម្មណ៍ថា ខ្លួនមិនសក្តិសម និងមិនមានគេចង់រាប់រក ក្នុងសង្គម។ ព្រះអង្គបានពន្យល់គេថា “ពួកអ្នកដែលជាសុខសប្បាយ គេមិនត្រូវការនឹងគ្រូពេទ្យទេ គឺជាមនុស្សដែលមានជំងឺវិញទេតើ ខ្ញុំមិនបានមក ដើម្បីហៅមនុស្សសុចរិតទេ គឺមកហៅតែមនុស្សមានបាបប៉ុណ្ណោះ ដើម្បីឲ្យគេប្រែចិត្តឡើង”(ម៉ាកុស ២:១៧)។



▶ យើងរាល់គ្នាបានសង្គ្រោះ ដោយសារព្រះគុណព្រះ គឺមិនមែនដោយសារចរិយាសម្បត្តិដ៏ល្អនោះឡើយ។

## ៥. តើការរស់នៅជាគ្រីស្ទបរិស័ទ មានការពិបាកទេ?

**ពេលណាយើងក្លាយជាគ្រីស្ទបរិស័ទ ព្រះទ្រង់ត្រាស់ហៅយើង ឲ្យផ្លាស់ប្រែ ឲ្យមានលក្ខណៈដូចព្រះយេស៊ូវ ដើម្បីបង្ហាញចេញនូវលក្ខណៈសម្បត្តិរបស់ព្រះយេស៊ូវ ដោយផ្លាស់ប្រែឲ្យមានចរិយាសម្បត្តិ ដូចព្រះអង្គ។** ការនេះហាក់ដូចជាពិបាក ឬមិនអាចធ្វើទៅរួចទេ ព្រោះយើងមានចំណុចខ្វះខាតច្រើនណាស់។

ប៉ុន្តែ ព្រះជាម្ចាស់មិនបានដាក់បន្ទុកធ្ងន់មកលើយើងឡើយ។ យើងមិនអាចព្យាយាមផ្លាស់ប្រែ ឲ្យក្លាយជាមនុស្សល្អ ដោយខ្លួនឯងនោះឡើយ។ ផ្ទុយទៅវិញ កាលណាយើងថ្វាយជីវិតដល់ព្រះ ហើយមានការប្រកបស្និទ្ធស្នាលជាមួយព្រះអង្គកាន់តែខ្លាំង ព្រះអង្គនឹងធ្វើការក្នុងជីវិតយើង ហើយព្រះអង្គនឹងកែប្រែចិត្តយើង ដើម្បីឲ្យយើងមានចិត្តចង់រស់នៅ តាមខ្នាតគំរូរបស់ព្រះអង្គ។ ហើយព្រះអង្គនឹងប្រទានលទ្ធភាពឲ្យយើងអាចធ្វើការទាំងនេះបាន។

ព្រះយេស៊ូវក៏បានធានាដល់យើងផងដែរថា ការដើរតាមព្រះអង្គ គឺមិនមានន័យថា យើងត្រូវទទួលបន្ទុកធ្ងន់នោះឡើយ។ ព្រះអង្គមានបន្ទូលថា “អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក ចូរទទួលនឹមខ្ញុំ ហើយរៀននឹងខ្ញុំចុះ ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព នោះអ្នករាល់គ្នានឹងបានសេចក្តីសំរាកដល់ព្រលឹង ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល”(ម៉ាថាយ ១១:២៨-៣០)។

ទន្ទឹមនឹងនោះ យើងត្រូវតែស្ម័គ្រចិត្ត និងត្រៀមខ្លួនដើម្បីស្វែងរកជំនួយមកពីព្រះ ដើម្បីលះបង់ចោលទម្លាប់ ការប្រព្រឹត្ត ឬអាកប្បកិរិយាណាមួយ ដែលមិនបានថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ ឬព្រះអង្គមិនសព្វព្រះទ័យ ហើយស្វែងរកជំនួយនៅក្នុងការធ្វើអ្វី ដែលព្រះអង្គសព្វព្រះទ័យ។ ព្រះគម្ពីរបានថែង អំពីអំពើបាប និងអាកប្បកិរិយា ដែលយើងត្រូវតែលះបង់ និងបុគ្គលិកលក្ខណៈល្អៗ ដែលយើងត្រូវមាន ខណៈពេលដែលយើងលូតលាស់ ក្នុងទំនាក់ទំនងជាមួយព្រះ។ “រីឯកិច្ចការខាងសាច់ឈាម នោះប្រាកដច្បាស់ហើយ គឺជាសេចក្តី កំផិត សហាយស្មន់ ស្មោកគ្រោក អាសអាភាស ថ្វាយបង្គំរូបព្រះ មន្តអាគម សំអប់គ្នា ឈ្លោះប្រកែក ឈ្នានីស កំហឹង ទាស់ទែងគ្នា បាក់បែក បក្សពួក ច្រណែន កាប់សំឡាប់ ប្រមឹក ស៊ីផឹកជ្រុល និងការអ្វីទៀត ដែលស្រដៀងនឹងសេចក្តីទាំងនេះផង ហើយខ្ញុំប្រាប់អ្នករាល់គ្នាទុកជាមុន ដូចជាបានប្រាប់រួចមកហើយថា អស់អ្នកដែលប្រព្រឹត្តដូច្នេះ នោះមិនបានគ្រងនគរព្រះ ទុកជាមរដកឡើយ តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្តីយ៉ាងនោះទេ”(កាឡាទី ៥:១៩-២៣)។

និយាយឲ្យខ្លី ការក្លាយជាគ្រីស្ទបរិស័ទ គឺជាការចូលទៅក្នុងការប្រកបស្និទ្ធស្នាលជាមួយព្រះ។ វាមិនមែនជាការព្យាយាមអនុវត្តតាមក្រឹត្យវិន័យ និងបទបញ្ញាអ្វីមួយ ដោយពឹងអាងកម្លាំងខ្លួនឯងនោះឡើយ។ ផ្ទុយទៅវិញ ខណៈពេលដែលអ្នកបានស្គាល់ព្រះយេស៊ូវកាន់តែច្បាស់ ហើយកាន់តែមានភាពជិតស្និទ្ធជាមួយព្រះអង្គ អ្នកនឹងមានចិត្តចង់រស់នៅ តាមរបៀបដែលព្រះអង្គសព្វព្រះទ័យ។ ទន្ទឹមនឹងនោះ ព្រះអង្គនឹងជួយអ្នក ឲ្យរស់នៅតាមព្រះទ័យព្រះអង្គ ដោយប្រទានកម្លាំង ប្រាជ្ញា និងការដឹកនាំ ដើម្បីដើរតាមគំរូរបស់ព្រះអង្គ។

# ស្វែងរកជំនួយពីព្រះ

**ជាការពិតណាស់ ការសម្រេចចិត្តដើរតាមព្រះយេស៊ូវ គឺតម្រូវឲ្យយើងមានការប្ដេជ្ញាចិត្ត។** ប៉ុន្តែ បើសិនជាអ្នកមានការពិបាក នៅក្នុងការប្ដេជ្ញាចិត្តដើរតាមទ្រង់ នោះមិនមែនមានតែអ្នកទេ ដែលជួបបញ្ហានេះ។ អ្នកខ្លះជួបការលំបាកដូចស៊ូ អានដែរ ដោយពួកគេបានសម្រេចចិត្តដើរតាមព្រះយេស៊ូវ ប៉ុន្តែ ពួកគេបានរង់ចាំមួយរយៈ មុននឹងទទួលបុណ្យជ្រមុជទឹក។ ពួកគេបានទទួលបុណ្យជ្រមុជទឹក បន្ទាប់ពីឪពុកម្ដាយរបស់ពួកគេយល់ស្របនឹងការសម្រេចចិត្តរបស់ពួកគេ។ អ្នកខ្លះទៀត មានបញ្ហាដូចហ៊ែនរីដែរ គឺពួកគេត្រូវការពេលវេលាមួយរយៈ ទំរាំតែអាចស៊ាំនឹងការទៅព្រះវិហារ នៅថ្ងៃអាទិត្យ។ ដូចនេះ សូមកុំអស់សង្ឃឹមឡើយ ព្រះទ្រង់ជ្រាប អំពីការស្ទាក់ស្ទើរ និងការសង្ស័យរបស់អ្នក។

ការដើរតាមព្រះយេស៊ូវ គឺជាការធ្វើដំណើរ ដែលក្នុងនោះ ព្រះទ្រង់នឹងសប្បាយព្រះទ័យ ពេលដែលអ្នកបោះជំហ៊ានទីមួយនៃជំនឿ ហើយបើអ្នកបន្តស្វែងរកព្រះអង្គ នោះព្រះអង្គនឹងប្រទានអ្នកនូវប្រាជ្ញា និងការដឹកនាំ ដើម្បីឲ្យអ្នកអាចដើរតាមព្រះអង្គ។ ព្រះអង្គមិនមែនជាព្រះដែលចូលចិត្តធ្វើការទាមទាមកលើយើងនោះឡើយ តែព្រះអង្គជាព្រះនៃសេចក្ដីស្រឡាញ់ ដែលសព្វព្រះទ័យឲ្យអ្នកដើរតាមព្រះអង្គដោយចិត្តស្មោះត្រង់។ សូមអធិស្ឋានយាងព្រះអង្គចូលគង់ក្នុងចិត្ត នោះព្រះវិញ្ញាណព្រះអង្គនឹងគង់ក្នុងចិត្តអ្នក ហើយដឹកនាំអ្នក ក្នុងការធ្វើដំណើរខាងវិញ្ញាណនេះ។ ព្រះអង្គមានបន្ទូលថា “ខ្ញុំមិនចោលអ្នករាល់គ្នាឲ្យនៅកំព្រាទេ ខ្ញុំនឹងមកឯអ្នករាល់គ្នាវិញ “តែព្រះដ៏ជាជំនួយ គឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មក ដោយនូវឈ្មោះខ្ញុំ ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្ដីទាំងអស់ ក៏នឹងរំឭកពីគ្រប់ទាំងសេចក្ដី ដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ”(យ៉ូហាន ១៤:១៨,២៦)។





▶ បើអ្នកមានអារម្មណ៍ថា អ្នកបានត្រៀមចិត្តដើម្បីដើរតាមព្រះយេស៊ូវ នោះយើងខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យធ្វើការសម្រេចចិត្តនៅពេលឥឡូវនេះ។

## ការសម្រេចចិត្ត

ការក្លាយជាគ្រីស្ទបរិស័ទ គឺមានន័យថា យើងទទួលស្គាល់ និងជឿដូចតទៅ:

- ព្រះជាម្ចាស់បង្កើតយើងមក ឲ្យ**មានទំនាក់ទំនងនៃសេចក្ដីស្រឡាញ់ជាមួយព្រះអង្គ**
- តែយើងម្នាក់ៗបាន**ទាស់ប្រឆាំងនឹងព្រះអង្គ** ដោយរស់នៅ តាមស្តង់ដារបស់យើង ហើយបានបដិសេធអំណាចរបស់ព្រះអង្គ
- ទង្វើរនេះគឺជា**អំពើបាប** ហើយទោសនៃអំពើបាប គឺជា**សេចក្ដីស្លាប់**
- ប៉ុន្តែ ព្រះទ្រង់បានប្រទាន**ដំណោះស្រាយ** មកយើងរាល់គ្នា ដោយចាត់**ព្រះរាជបុត្រាព្រះអង្គ ព្រះយេស៊ូវគ្រីស្ទ**ឲ្យសុគតជំនួសយើង។
- ព្រះយេស៊ូវបានសុគត តែបីថ្ងៃក្រោយមក **ព្រះអង្គមានព្រះជន្មរស់ឡើងវិញ** ដោយបង្ហាញថា ព្រះជាម្ចាស់បានទទួលយកការលះបង់ដែលព្រះអង្គបានធ្វើជំនួសយើង។
- **នេះជាអំណោយនៃសេចក្ដីសង្គ្រោះ** ដែលក្នុងនោះ យើងមិនសមនឹងទទួលការអត់ទោសបាប តែយើងអាចទទួលការអត់ទោសបាប និងសេចក្ដីសង្គ្រោះ ដោយព្រះគុណរបស់ព្រះអង្គ តាមរយៈសេចក្ដីជំនឿរបស់យើង គឺគ្មានមធ្យោបាយណាផ្សេងទៀតឡើយ។

តាមពិត ការអះអាងខាងលើនេះ គឺជាសេចក្ដីពិតជាមូលដ្ឋាន នៃដំណឹងល្អ ជាសេចក្ដីពិតតែមួយគត់ ដែលនាំឲ្យអ្នកទទួលសេចក្ដី

សង្គ្រោះ។ ព្រះទ្រង់នឹងជួយអ្នក ឲ្យអាចជម្នះបញ្ហាលំបាក ដែលអ្នកមាន នៅក្នុងការសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ទៅព្រះវិហារ និងរស់នៅជាគ្រីស្ទបរិស័ទ ខណៈពេលដែលអ្នកចាប់ផ្តើមការធ្វើដំណើរជាមួយព្រះអង្គ។

បើអ្នកបានត្រៀមខ្លួន ដើម្បីដើរតាមព្រះយេស៊ូវហើយ នោះខ្ញុំសូមលើកទឹកចិត្តអ្នក ឲ្យធ្វើការសម្រេចចិត្តនៅពេលឥឡូវនេះ។ ចូរទូលដល់ព្រះថា អ្នកជឿព្រះយេស៊ូវ ដែលជាព្រះរាជបុត្រាព្រះអង្គ ហើយជឿថា ព្រះអង្គសុគតជំនួសអ្នក នៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ ហើយអ្នកបានត្រៀមខ្លួនដើម្បីទទួលជឿព្រះអង្គ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ។ ព្រះជាម្ចាស់តែងតែស្តាប់អ្នកជានិច្ច ដូចនេះ អ្វីដែលអ្នកត្រូវធ្វើ គឺត្រូវនិយាយទៅកាន់ទ្រង់ គឺហាក់ដូចជាទ្រង់កំពុងតែនៅពីមុខអ្នក។ បើសិនជាអាច សូមស្វែងរកមិត្តភក្តិជាគ្រីស្ទបរិស័ទ ឲ្យអធិស្ឋានជាមួយអ្នក និងធ្វើជាសាក្សីរបស់អ្នក។

អ្នកអាចសម្រេចចិត្តទទួលជឿព្រះយេស៊ូវ នៅពេលឥឡូវនេះបាន! អ្នកអាចអធិស្ឋានទទួលជឿព្រះអង្គ តាមលំនាំខាងក្រោមនេះ។ ពាក្យពេចន៍ខាងក្រោមនេះ គឺគ្រាន់តែជាលំនាំនៃការអធិស្ឋាន តែដែលសំខាន់បំផុតនោះ គឺអ្នកបានអធិស្ឋានចេញចិត្តរបស់អ្នក :

*ព្រះអម្ចាស់យេស៊ូវអើយ ទូលបង្គំត្រូវការព្រះអង្គ។ សូមអរព្រះគុណព្រះអង្គ ដែលបានសុគតនៅលើឈើឆ្កាងជំនួសទូលបង្គំ។ ទូលបង្គំសូមបើកចិត្តទូលបង្គំ ទទួលព្រះអង្គធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់របស់ទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានអត់ទោសបាបឲ្យទូលបង្គំ ហើយប្រទានជីវិតអស់កល្បជានិច្ចដល់ទូលបង្គំ។ សូមព្រះអង្គយាងមកសោយរាជ្យ លើបល្ល័ង្កជីវិតទូលបង្គំ។ សូមកែច្នៃទូលបង្គំឲ្យទៅជាមនុស្សដែលព្រះអង្គសព្វព្រះហឫទ័យ អាម៉ែន។*

ព្រះជាម្ចាស់តែងតែស្តាប់យើងជានិច្ច ដូចនេះ អ្វីដែលយើងត្រូវធ្វើ នោះគឺត្រូវនិយាយទៅកាន់ព្រះអង្គ គឺហាក់ដូចជាព្រះអង្គកំពុងតែនៅពីមុខយើង។ បើសិនជាអាច សូមឲ្យមិត្តភក្តិជាគ្រីស្ទបរិស័ទ អធិស្ឋានជាមួយអ្នក។






បើសិនជាលោកអ្នកចង់ស្វែងយល់បន្ថែមអំពីព្រះយេស៊ូវ និងអំពីការអ្វីដែលព្រះអង្គបានធ្វើសម្រាប់អ្នក សូមទាញយក ឬdownload សៀវភៅ រឿងនៃក្តីសង្ឃឹម តាមអាស័យដ្ឋាន :

https://khmer-odb.org/ds/story-of-hop/

**Scan the QR Code** to read it online, or contact us if you would like to receive a a print copy.

We invite you to also check out **odb.org** to view our other printed and digital resources.